# របាយការណ៍របស់អគ្គលេខាធិការ អ.ស.ប ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ដែលនឹងត្រូវបង្ហាញនាសម័យប្រជុំរបស់ ក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០

នៅថ្ងៃទី០៥ខែតុលាឆ្នាំ២០២០របាយការណ៍របស់អគ្គលេខាធិការ អ.ស.ប ស្តីពីសិទ្ធិមនុស្សនៅកម្ពុជានឹងត្រូវបង្ហាញជូនក្រុមប្រឹក្សាសិទ្ធិមនុស្សនៅទីក្រុងហ្សឺណែវ។ សម័យប្រជុំនេះ នឹងចាប់ផ្តើមនៅ ម៉ោង ១៥.00 ម៉ោង នៅទីក្រុង ហ្សឺណែវ (ត្រូវនឹង ម៉ោង ២០.00 ម៉ោង នៅរាជធានីភ្នំពេញ) ជាមួយនឹងការធ្វើបច្ចុប្បន្នភាពផ្ទាល់មាត់ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា នាយកផ្នែកប្រតិបត្តិការនិងកិច្ចសហប្រតិបត្តិការបច្ចេកទេសប្រចាំតំបន់ នៃការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដែលមានការចូលរួមពីរដ្ឋជាសមាជិកអ.ស.បនិងអង្គការសង្គមស៊ីវិលនានា។សម័យប្រជុំទាំងមូលនឹងត្រូវបានផ្សាយផ្ទាល់នៅលើវេបធីរ http://webtv.un.org ។

របាយការណ៍នេះ ផ្តោតលើការងាររបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (ការិយាល័យ OHCHR) និងស្ថានភាពសិទ្ធិមនុស្ស ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ ដល់ ថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ២០២០។ លោកអគ្គលេខាធិការលើកឡើងពីកង្វល់មួយចំនួនអំពីការរួមតូចនៃលំហាពលរដ្ឋ និងភាពតានតឹងផ្នែកនយោបាយនៅតែបន្តមាន ទន្ទឹមនឹងនេះ លោកក៏គូសបញ្ជាក់ផងដែរ អំពីតួនាទីរបស់ការិយាល័យ OHCHR ក្នុងការផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេស ដើម្បីការពង្រឹងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ការពារសេរីភាពជាមូលដ្ឋាន និងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រួមទាំងក្នុងបរិបទនៃការរាតត្បាតដោយជំងឺកូវីដ-១៩។ ខាងក្រោមនេះ គឺសេចក្តីសង្ខេបចំណុច គន្លឹះៗ និងអនុសាសន៍មួយចំនួនរបស់លោកអគ្គលេខាធិការ។

## ពង្រឹងការចូលរួម និងការពារលំហាពលរដ្ឋ

របាយការណ៍នេះ បង្ហាញពីការបង្ក្រាបខាងនយោបាយកាន់តែខ្លាំងឡើងនៅក្នុងប្រទេស ដែលយ៉ាងហោចណាស់ក៏មានមនុស្សចំនួន ១៤០ នាក់ ដែរ ដែលជាប់ទាក់ទងជាមួយអតីតគណបក្សសង្គ្រោះជាតិកម្ពុជា ត្រូវបានចាប់ខ្លួន។ លោកអគ្គលេខាធិការសំដៅដល់កង្វល់ដែលអ្នកជំនាញសិទ្ធិមនុស្ស អ.ស.ប បានលើកឡើង អំពីករណីលោក កឹម សុខា រួមទាំងមូលដ្ឋានរឹងមាំដែលអាចជឿបានថា បទចោទក្បត់ជាតិ គឺជាហេតុផលនយោបាយ និងជាផ្នែកមួយនៃលំនាំដ៏ធំមួយនៃការប្រើប្រាស់ច្បាប់មិនត្រឹមត្រូវ ដែលតម្រង់គោលដៅទៅលើគូប្រជែងនយោបាយ និងអ្នករិះគន់រដ្ឋាភិបាល។ អាស្រ័យហេតុនេះ លោកអគ្គលេខាធិការអំពាវនាវដល់រដ្ឋាភិបាល និងអ្នកនយោបាយដទៃទៀតឱ្យចូលរួមក្នុងការសន្ទនា ដើម្បីកាត់បន្ថយភាពតានតឹងនិងស្តារឡើងវិញទាំងស្រុងនូវសិទ្ធិសេរីភាពក្នុងការ បញ្ចេញមតិ សិទ្ធិបង្កើតសមាគមនិងការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិចូលរួមដឹកនាំកិច្ចការសាធារណៈ។

លោកអគ្គលេខាធិការគូសបញ្ជាក់ផងដែរ អំពីការបំភិតបំភ័យទៅលើសង្គមស៊ីវិល និងអង្គការសិទ្ធិមនុស្សផ្សេងៗ ដែលរារាំងដល់សមត្ថភាពរបស់ពួកគេក្នុងការឃ្លាំមើលនិងរាយការណ៍។របាយការណ៍របស់លោកបញ្ជាក់ថា មាន ៤៦ ករណី ដែលសកម្មភាពរបស់អង្គការសិទ្ធិមនុស្ស និងអង្គការសង្គមស៊ីវិលមួយចំនួន បានទទួលរងនូវការជ្រៀតជ្រែករំខាន ការបំភិតបំភ័យ ឬការឃាយីពីសំណាក់អាជ្ញាធរ។ លោកអំពាវនាវឱ្យរដ្ឋាភិបាលពង្រឹងលំហាពលរដ្ឋ និងលំហប្រជាធិបតេយ្យ រួមទាំងតាមរយៈការធានា ការងារសិទ្ធិមនុស្ស និងអង្គការសង្គមស៊ីវិល និងក្រុមសហគមន៍ ដោយគ្មានការរារាំង តាមរយៈការពង្រីកលំហប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល និងក្រុមសហគមន៍ទាំងនោះ។

របាយការណ៍បានគូសបញ្ជាក់ផងដែរ អំពីការរឹតត្បិតហួសហេតុលើសិទ្ធិសេរីភាពបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធីរួមទាំងការចាប់ខ្លួនបុគ្គលមួយចំនួន ដោយសារតែការអត្ថាធិប្បាយជាសាធារណៈ និងការបង្ហោះលើបណ្តាញសង្គមទាក់ទងនឹងជំងឺកូវីដ-១៩។ ក្នុងន័យនេះ អគ្គលេខាធិការអំពាវនាវឱ្យរដ្ឋាភិបាលធានាថា រាល់វិធានការវិសាមញ្ញណាមួយ ដែលឱ្យដាក់អនុវត្ត សំដៅការពារសុខភាព និងសុខុមាលភាពរបស់ប្រជាជន ក្នុងអំឡុងពេលមានការរាតត្បាតនៃជំងឺកូវីដ-១៩ គឺជាការធ្វើឡើងបណ្តោះអាសន្ន សមាមាត្រ ចាំបាច់បំផុត សម្រាប់ការបង្ការការរីករាលដាល និងការព្យាបាលនៃជំងឺនេះ ដោយគ្មានការរើសអើង និងស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជាតែប៉ុណ្ណោះ។

## ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌

របាយការណ៍នេះ និយាយដល់ការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងស្ថានភាពអាសន្នដែលបានចូលជាធរមានក្នុងខែ មេសា ឆ្នាំ២០២០ ។ លោកអគ្គលេខាធិការ គូសបញ្ជាក់ថា ច្បាប់នេះអនុញ្ញាតឲ្យដាក់ការរឹតត្បិតលើសិទ្ធិសេរីភាពក្នុងការដើរហើរ និងការជួបប្រជុំ សិទ្ធិទទួលបានព័ត៌មាន សិទ្ធិឯកជន ហើយលោកបានសំដែងកង្វល់ទាក់ទងនឹងការអនុម័តច្បាប់ជាបន្ទាន់ បទប្បញ្ញត្តិមិនច្បាស់លាស់ ទាក់ទងនឹងបដិប្បញ្ញត្តិ និងការពិនិត្យឡើងវិញ និងការត្រួតពិនិត្យមិនគ្រប់គ្រាន់។

ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌លោកអគ្គលេខាធិការគូសបញ្ជាក់ពីការងារដែល ការិយាល័យ OHCHR បានធ្វើក្នុងការសង្កេតមើលការជំនុំជម្រះក្តីច្រើនជាង ៣៥ ករណី នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ របាយការណ៍កត់សម្គាល់ពីការអនុវត្តមិនស៊ីសង្វាក់គ្នា ដែលមិនស្របតាមច្បាប់សិទ្ធិមនុស្សជាតិ និងអន្តរជាតិ ជាពិសេស សិទ្ធិទទួលបានការដឹងភ្លាមៗពីការចោទប្រកាន់ សិទ្ធិមានតំណាងស្របច្បាប់ និងការសន្មត់ជាមុនថាគ្មានទោសរហូតដល់មានពិរុទ្ធភាព។ លោកអគ្គលេខាធិការលើកទឹកចិត្តឱ្យរដ្ឋាភិបាលធានាការពារសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ រួមទាំងការអនុម័តគោលនយោបាយជាតិ ស្តីពីជំនួយផ្នែកច្បាប់ និងការបង្កើតឱ្យមានប្រព័ន្ធជំនួយផ្នែកច្បាប់ដែលមានលក្ខណៈប្រមូលផ្តុំ។

ទាក់ទងនឹងស្ថានភាពពន្ធនាគារ របាយការណ៍លើកឡើងពីកង្វល់អំពីចំនួនជនជាប់ឃុំក្នុងពន្ធនាគារនៅកម្ពុជា ដែល បន្តកើនឡើងជាលំដាប់។ ការប្រើជម្រើសផ្សេងក្នុងការឃុំខ្លួនរួមទាំងការដាក់ប្រាក់ធានាឱ្យនៅក្រៅឃុំ ក្រោមការត្រួតពិនិត្យរបស់តុលាការ និងការព្យួរទោសនៅតែមានកំណត់នៅឡើយ។ លោកអគ្គលេខាធិការ ជំរុញលើកទឹកចិត្តឱ្យរដ្ឋាភិបាលណែនាំអនុវត្តវិធានការ និងជម្រើសជំនួសការឃុំខ្លួនសំដៅកាត់បន្ថយភាពចង្អៀតណែនក្នុងពន្ធនាគារ និងដើម្បីបង្កើតគោលការណ៍ណែនាំ និងនីតិវិធី ដើម្បីកាត់បន្ថយការអូសបន្លាយរយៈពេលឃុំខ្លួនបណ្តោះ អាសន្ន និងពន្យាពេលដោះលែងបន្ទាប់ពីបានបម្រើទោសចប់ហើយ ដើម្បីពិនិត្យមើលការហាមប្រាមលើការកាត់បន្ថយទោស និងការលើកលែងទោសចំពោះបទល្មើសទាក់ទងនឹងគ្រឿងញៀន។ លោកអំពាវនាវផងដែរ ដល់រដ្ឋាភិបាលឱ្យផ្តល់ការអនុញ្ញាតដល់ការិយាល័យ OHCHR ធ្វើទស្សនកិច្ចនៅគ្រប់ទីកន្លែងដែលមានការឃុំខ្លួនមនុស្ស រួមទាំងការសម្ភាសជាសម្ងាត់ជាមួយជនជាប់ឃុំ។

## សិទ្ធិសេដ្ឋកិច្ច និងសង្គម

លោកអគ្គលេខាធិការ កត់សម្គាល់ឃើញបញ្ហាប្រឈមនៅតែមានក្នុងវិស័យដីធ្លី និងសិទ្ធិលំនៅដ្ឋាន ជាពិសេសទាក់ទងនឹងការបណ្តេញចេញដោយបង្ខំ កង្វះបទដ្ឋានត្រឹមត្រូវស្តីពីការតាំងទីលំនៅថ្មី និងរយៈពេលវែង ស្មុគស្មាញ មិនច្បាស់លាស់ និងការចំណាយប្រាក់ច្រើនក្នុងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី។ របាយការណ៍គូសបញ្ជាក់ថា ការបែងចែក ការលក់ និងការប្រើប្រាស់ដីធ្លីបានបន្តដំណើរការតាមប្រព័ន្ធផ្តល់សិទ្ធិអំណាចសម្រាប់ប្រទានយសសក្ក ដែលមានវិសមភាពរចនាសម្ព័ន្ធ ដែលជះឥទ្ធិពលមិនសមមាត្រទៅលើបុគ្គលដែលរស់នៅក្នុងភាពក្រីក្រ និងក្នុងស្ថានភាពងាយរងគ្រោះ។ ក្នុងវិស័យនេះលោកអគ្គលេខាធិការ ជំរុញលើកទឹកចិត្តឱ្យរដ្ឋាភិបាល ពន្លឿនដល់ដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិសហគមន៍ សម្រាប់ជនជាតិដើមភាគតិច។ ទាក់ទងនឹងការបណ្តេញចេញ និងការតាំងទីលំនៅថ្មី លោកអគ្គលេខាធិការជំរុញលើកទឹកចិត្តឱ្យរដ្ឋាភិបាលអនុម័តគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី ដែលស្របតាមគោលការណ៍ និងគោលការណ៍ណែនាំជាមូលដ្ឋាន ស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មីដោយផ្អែកលើការអភិវឌ្ឍ។

ទោះបីជាមានការទទួលស្គាល់នូវវិធានការវិជ្ជមានរបស់រដ្ឋាភិបាលក្នុងការដោះស្រាយការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដោយ ក៏លោកអគ្គលេខាធិការ កត់សម្គាល់ឃើញនូវកង្វះព័ត៌មានដែលអាចរកបានស្តីពីការឆ្លើយតបនឹងជំងឺកូវីដ-១៩ របស់រដ្ឋាភិបាល រួមមាន ទីតាំងវេជ្ជសាស្ត្រ ពិធីសារដាក់ឲ្យដាច់ដោយឡែក បុគ្គលិកវេជ្ជសាស្ត្រជំនាញ និងលទ្ធភាពរកបាននូវឧបករណ៍ចាំបាច់។ ការធ្វើតេស្តជំងឺកូវីដ-១៩ ក៏មានកំណត់ផងដែរ និងមានការរឹតត្បិតយ៉ាងតឹងរឹង ហើយមានភាពមិនទាន់ច្បាស់ក្នុងការទទួលបានសេវាពីសហគមន៍តាមជនបទងាយរងគ្រោះ និងបាត់បង់ឱកាស។ លោកអគ្គលេខាធិការ អំពាវនាវឱ្យរដ្ឋាភិបាល ធានាសិទ្ធិទទួលបានព័ត៌មានអំពីការការពារក៏ដូចជាការធ្វើតេស្ត និងការព្យាបាល សម្រាប់ជនគ្រប់រូប ក្នុងអំឡុងពេលមានការរាតត្បាតនៃជំងឺកូវីដ-១៩ និងដើម្បីធានាថាវិធីសាស្ត្រដែលផ្អែកលើសិទ្ធិត្រូវបានដាក់បញ្ចូល ក្នុងគ្រប់ពិធីសារជាតិស្តីពីគ្រោះមហន្តរាយ និងពិធីសារភាពអាសន្នផ្នែកសុខភាព។ លោកអំពាវនាវផងដែរឱ្យរដ្ឋាភិបាលណែនាំអនុវត្តវិធានការពិសេស ដើម្បីការពារក្រុម និងបុគ្គលទាំងឡាយដែលស្ថិតក្នុងស្ថានភាពដែលងាយរងគ្រោះ ជាពិសេស ដោយការរាតត្បាតនៃជំងឺកូវីដ-១៩រួមទាំងជនជាតិដើមភាគតិច និងជនជាតិភាគតិច សហគមន៍ក្រីក្រ និងសហគមន៍ជនបទ សហគមន៍អណ្តែតទឹក ជនចំណាកស្រុកដែលធ្វើមាតុភូមិនិវត្ត បុគ្គលដែលត្រូវគេដកហូតសេរីភាព បុគ្គលដែលត្រូវគេដាក់ឱ្យនៅដាច់ដោយឡែក ស្ត្រីមានផ្ទៃពោះ ជនពិការ មនុស្សចាស់ជរា និងបុគ្គលដែលមានជំងឺប្រចាំកាយ។

របាយការណ៍ទាំងស្រុង មាននៅលើគេហទំព័រ
https://undocs.org/A/HRC/45/56